ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

អាជ្ញាធរអប្សរា
APSARA
N° ៣១៧ ប្រជុំសលណ

# សេចក្តីជូនដំណឹង
## ដល់បងប្អូនអាជីវករទាំងអស់ដែលកំពុងលក់ដូរ និងប្រកបរបររក
## កម្រៃផ្សេងៗនៅតាមប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ

**អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា** សូមជម្រាបជូនដំណឹងដល់បងប្អូនអាជីវករដែលកំពុងលក់ដូរនៅតាមប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរមេត្តាជ្រាបថា៖ រមណីយដ្ឋានអង្គរត្រូវបានកាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោក ដែលអាជ្ញាធរអប្សរាមានតួនាទី និងភារកិច្ចធ្វើការ អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ នាពេលបច្ចុប្បន្នអាជ្ញាធរអប្សរាសង្កេតឃើញថា នៅតាមកន្លែងលក់ដូរ និងតាមទីសាធារណៈដូចជា នៅតាមដើមឈើ តាមបង្គោលភ្លើង និងនៅក្រៅគេហដ្ឋាននានាមានការតាំងដាក់នូវស្លាកសញ្ញាផ្សព្វផ្សាយ ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់ទេសភាពវប្បធម៌នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

អាស្រ័យហេតុនេះ ដើម្បីរក្សានូវតម្លៃអង្គរដែរជាសម្បត្តិវប្បធម៌ដ៏មានតម្លៃមិនអាចកាត់ថ្លៃបានរបស់ដូនតាយើង និងជាបេតិកភ័ណ្ឌពិភពលោកផងនោះ ដូចនេះសូមបងប្អូនអាជីវករដែលជាម្ចាស់ភោជនីយដ្ឋាន ម្ចាស់តូបលក់ដូរ និងសំណង់ផ្សេងៗនៅតាមប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់ ត្រូវរុះស្លាកសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់រូបភាពទាំងនោះឲ្យអស់ក្នុងរយៈពេល៣០ថ្ងៃក្រោយពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ។ ក្នុងករណីបងប្អូនអាជីវករទាំងអស់មិនអនុវត្តតាមសេចក្តីជូនដំណឹងខាងលើនេះទេ **អាជ្ញាធរអប្សរា** នឹងមានវិធានការជាក់ស្តែងដោយពុំទទួលខុសត្រូវចំពោះការខាតបង់ផ្សេងៗឡើយ។

ចំពោះស្លាកសញ្ញាដែលមិនមែនជាស្លាសញ្ញាពាណិជ្ជកម្ម សូមអញ្ជើញបងប្អូនមកដាក់ពាក្យស្នើសុំនៅមជ្ឈមណ្ឌលសេវាកម្ម នៃអាជ្ញាធរអប្សរា។

សូម បងប្អូនអាជីវករលក់ដូរទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

សៀមរាប ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ២០១២

អគ្គនាយក

ប៊ុន ណារិទ្ធ

**ចម្លងជូន៖**
- សាលាខេត្តសៀមរាប
-ស្នងការនគបាលខេត្តសៀមរាប
-សាលាក្រុងសៀមរាប
-អង្គភាពនគរបាល ការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍
"ដើម្បីជ្រាប និងសុំកិច្ចសហការ"
-គ្រប់នាយកដ្ឋាននៃអាជ្ញាធរអប្សរា "ដើម្បីជ្រាប និងមុខការ"
-ឯកសារ- កាលប្បវត្តិ

អាជ្ញាធរជាតិអប្សរា ការពារតំបន់និងរៀបចំដែនដីអង្គរ
AUTORITE POUR LA PROTECTION DU SITE ET L'AMENAGEMENT DE LA REGION D' ANGKOR
Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

PHNOM PENH :
#167, Pasteur St, Chaktomok, Daun Penh
Téléphone : (855-23) 720 315, 721 150
Télécopie : (855-23) 990 185

SIEM REAP :
Avenue 60m, Cité culturelle et touristique
Téléphone : (855-63) 765 577, 766 676
Télécopie : (855-63) 765 576